**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ....០.១៤....សស·ចប

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០០៧

# ប្រកាស

## ស្តីពី

## ការបង្កើតការិយាល័យសុខភាពផ្លូវចិត្ត

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

## សម្រេច

**ប្រការ ១.-**

បង្កើតការិយាល័យសុខភាពផ្លូវចិត្ត ឱ្យស្ថិតក្រោមចំណុះនាយកដ្ឋានមន្ទីរពេទ្យ នៃក្រសួងសុខាភិបាល

ប្រធានកម្មវិធីជាតិសុខភាពផ្លូវចិត្ត ត្រូវសហការជាមួយប្រធាននាយកដ្ឋានមន្ទីរពេទ្យ ក្នុងការអនុវត្តការងារចាំបាច់ ។

**ប្រការ ២.-**

ការិយាល័យសុខភាពផ្លូវចិត្ត មានបេសកកម្ម ដូចតទៅ :

- អភិវឌ្ឍន៍គោលនយោបាយក្រសួងសុខាភិបាល សំរាប់ការិយាល័យសុខភាពផ្លូវចិត្ត
- អភិវឌ្ឍន៍ និងពង្រឹងការផ្តល់សេវាសុខភាពផ្លូវចិត្ត អោយកាន់តែទូលំទូលាយថែមទៀត ព្រមទាំងផ្តល់ការគាំទ្រ ផ្នែកបច្ចេកទេសដល់មន្ទីរសុខាភិបាលខេត្ត-ក្រុង ស្រុកប្រតិបត្តិ និង មូលដ្ឋានសុខាភិបាល ក្នុងការលើកកំពស់គុណភាពសេវា
- ចូលរួមកសាងសមត្ថភាពធនធានមនុស្សសំរាប់សកម្មភាពសុខភាពផ្លូវចិត្ត តាមរយៈការបណ្តុះបណ្តាល ដោយសហការជាមួយគ្រឹះស្ថានបណ្តុះបណ្តាល នៃក្រសួងសុខាភិបាល និង ស្ថាប័នពាក់ព័ន្ធដទៃទៀត

- ធ្វើការស្រាវជ្រាវ ស្តីពីសុខភាពផ្លូវចិត្ត និង បញ្ហាដែលជាប់ទាក់ទង ព្រមទាំងត្រួតពិនិត្យតាមដានវឌ្ឍនភាព និង សមិទ្ធផល នៃការអនុវត្តន៍សកម្មភាពរបស់ការិយាល័យសុខភាពផ្លូវចិត្ត ដើម្បីទ្រទ្រង់ដល់ការគ្រប់គ្រង និង ការធ្វើផែនការ របស់ការិយាល័យសុខភាពផ្លូវចិត្ត ទូទាំងប្រព័ន្ធសុខាភិបាល
- ពង្រឹងការសំរបសំរួលរវាង ដៃគូទាំងអស់ រួមមានអង្គភាពនានា របស់ក្រសួងសុខាភិបាល និង វិស័យផ្សេងទៀត ដើម្បីអភិវឌ្ឍវិស័យសុខភាពផ្លូវចិត្ត ព្រមទាំងធានាថាធនធានទាំងនោះ ត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាព ។

**ប្រការ ៣.-**

ការិយាល័យសុខភាពផ្លូវចិត្ត ត្រូវដឹកនាំដោយប្រធាន ០១ រូប និងមានអនុប្រធានមួយចំនួន តាមការចាំបាច់ ។

**ប្រការ ៤.-**

រាល់សេចក្តីសំរេចណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥.-**

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គាធិការដ្ឋាន ខុទ្ទកាល័យក្រសួងសុខាភិបាល នាយកដ្ឋានមន្ទីរពេទ្យ និងអង្គភាពក្រោមឱវាទក្រសួងសុខាភិបាលទាំងអស់ មានភារៈអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

ដុ. នុត-សុខុម

**កន្លែងទទួល ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសុខាភិបាល
- ដូចមាត្រា ៥
- ឯកសារ
- កាលប្បវត្តិ